**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ.........៧០១.............ក. ស. ភ.

ថ្ងៃពុធ ១០កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមពិគ្រោះថ្លៃ
## ការងារចំនួន ២គម្រោង នៅចំណតផែកុងតឺន័រLM១៧ រួមមាន៖
## ១-គម្រោងដំឡើងទូអូស្តូការិយាល័យទំហំ ៤០ហ្វីត ចំនួន ១គ្រឿង
## សម្រាប់កម្មករនិយោជិតរង់ចាំបំពេញការងារ និង២-ការងារជួសជុលច្រកទ្វារចេញ-ចូល
## ចំនួន ៣ទីតាំង

កំពង់ផែស្វយ័តភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា កំពង់ផែស្វយ័តភ្នំពេញនឹងដាក់ឱ្យពិគ្រោះថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការណ៍លើ ការងារចំនួន ២គម្រោង នៅចំណតផែកុងតឺន័រLM១៧ រួមមាន៖ ១-គម្រោងដំឡើងទូអូស្តូការិយាល័យទំហំ ៤០ហ្វីត ចំនួន ១គ្រឿង សម្រាប់កម្មករនិយោជិតរង់ចាំបំពេញការងារ និង ២-ការងារជួសជុលច្រកទ្វារចេញ-ចូល ចំនួន ៣ទីតាំង ។

កំពង់ផែស្វយ័តភ្នំពេញបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃឯកសារពិគ្រោះថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្ម នៃកំពង់ផែស្វយ័តភ្នំពេញដែលមានអាសយដ្ឋានអគារ លេខ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី......២៥......ខែ.មិថុនា... ឆ្នាំ២០២៦តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទំនាក់ទំនងលេខ ០១០ ៤៤៤ ៣១៣ / ០១០ ៤៤៤ ៦៣៤)។

កាលបរិច្ឆេទឈប់ទទួលពាក្យសំណើពិគ្រោះថ្លៃនៅ**វេលាម៉ោង**១៤:៣០..នាទីថ្ងៃទី.៩.....ខែកក្កដា..ឆ្នាំ២០២៦។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ **វេលាម៉ោង**១៤:៣០.នាទី **ថ្ងៃទី**...៩.....**ខែ**.កក្កដា... **ឆ្នាំ២០២៦។**

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ។

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ជួន សុខេម**